**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង  មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី
## ការរៀបចំនិយាមប្រតិបត្តិដើម្បីដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
## នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

- *ឯកឧត្តម លោកជំទាវ គណៈអធិបតី*
- *លោកស្រី វ៉ាងវ៉ាំងកា អាន់ដ្រីវ៉ា ប្រធានអង្គការយូអិនអេដស៍ (UNAIDS) ប្រចាំកម្ពុជា*
- *អស់លោក លោកស្រីជាតំណាងក្រសួង មន្ទីរដែលជាសមាជិករបស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *អ្នកតំណាងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល*
- *អ្នកតំណាងប្រជាជនប្រឈមមុខខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍*
- *អស់លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីរាប់អាន*

ជាបឋម តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកថ្លែងក្នុងពិធីបើក ***កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំនិយាមប្រតិបត្តិដើម្បីដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់*** ដ៏មានសារៈសំខាន់នាពេលនេះ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលអញ្ជើញមកពីក្រសួងមន្ទីរពាក់ព័ន្ធមួយចំនួន និងជាពិសេសតំណាងអាជ្ញាធរដែនដីឃុំ-សង្កាត់ នៃរាជធានីភ្នំពេញព្រមទាំងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលអ្នកតំណាងប្រជាជនគន្លឹះ ចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ។

*គោលបំណងនៃកិច្ចប្រជុំពិគ្រោះយោបល់នាថ្ងៃនេះគឺ យើងចង់ប្រមូលយកនូវមតិយោបល់របស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីក្នុងការរៀបចំនូវនិយាមប្រតិបត្តិមួយដែលផ្តល់នូវការណែនាំ និងគាំទ្រ ក្នុងការសម្របសម្រួលឱ្យឃុំសង្កាត់អនុវត្តនូវអន្តរាគមន៍ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសេវាពាក់ព័ន្ធនានាក្នុងចំណោមប្រជាជនគន្លឹះ និងប្រជាជនទូទៅដែលជា*